សាលាដំបូងខេត្តកណ្ដាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
កណ្ដាល ថ្ងៃទី០៩ ខែ៦ ឆ្នាំ ២០១៤
ក្រឡាបញ្ជី
ព្រំ-ចាន់ថា

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០៤០
ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១
សាលក្រមលេខ៖ ០២ (ឥ.រ.ន)
ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាលនាថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង ៩ ព្រឹកដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោ[redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក[redacted] ចៅក្រមប្រឹក្សា

លោក[redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក[redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក[redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ០៤០ អក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ដែលមានជនជាប់ចោទ៖

ឈ្មោះ: [redacted]ភេទប្រុស អាយុ៥៤ ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិថ្មី ឃុំថ្មី ស្រុកកំពង់រោ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅភូមិព្រៃកល្លា ឃុំព្រៃគគីរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឪពុកឈ្មោះ:[redacted]) ម្ដាយឈ្មោះ:[redacted]ពន្ធឈ្មោះ:[redacted] (I) មានកូនចំនួន ០២ នាក់។

ត្រូវបានជាប់ចោទពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិព្រៃកល្លា ឃុំព្រៃគគីរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីខែសីហា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

មេធាវីការពារជនជាប់ចោទឈ្មោះ:[redacted]

Scanned by CamScanner

<u>**ដំណើរអង្គហេតុមានដូចតទៅ**</u>

កាលពីខែសីហា ឆ្នាំ២០១០ វេលាម៉ោង ១៧ និង០០នាទី ជនរងគ្រោះឈ្មោះ[redacted] ភេទស្រី អាយុ ៩ឆ្នាំ កំពុងដេកនៅលើផ្ទះ ស្ថិតនៅភូមិល្វា ឃុំព្រៃកតាក្វ ស្រុកខ្សាចកណ្ដាល ខេត្តកណ្ដាល ជាមួយជនត្រូវចោទឈ្មោះ[redacted]បន្ទាប់មកឈ្មោះ[redacted]បានមកដេកទ្រាបពីលើជនរងគ្រោះឈ្មោះ[redacted] ហើយបានគំរាមនាងមិនឲ្យស្រែក និងបានចាប់ស្រាតខោរបស់នាង និងស្រាតខោខ្លួន នៅពេលនោះឈ្មោះ[redacted]បានបញ្ចេញប្រដាប់ភេទរបស់ខ្លួនបំរ៉ុងដាក់បញ្ចូលទៅក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ តែចៃដន្យឈ្មោះ[redacted]និងឈ្មោះ[redacted] បានឡើងមកទាន់ ភ្លាមនោះឈ្មោះ[redacted]បានរត់គេចខ្លួនតែម្ដង។

បានឃើញ ដីកាសន្និដ្ឋានស្ដាពរលេខ៖ ៦១៧ ដកសព ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣។

បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ៖ ៤១៩ ចុះថ្ងៃទី០២ ខែ កញ្ញា ឆ្នាំ២០១៣។

បានឃើញ ចំណារចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣។

**នាពេលសវនាការ**

-អំណានចម្លើយជនរងគ្រោះឈ្មោះ[redacted] បានឆ្លើយថា៖ ខ្លួនមិនបានចាំថ្ងៃខែឆ្នាំទេ វេលាម៉ោងប្រហែល ៥ ល្ងាច ខ្លួនកំពុងអង្គុយលើផ្ទះនៅក្នុងភូមិព្រៃកល្វា ឃុំព្រៃកតាក្វ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល តែម្នាក់ឯង ចំណែកម៉ីងខ្លួនឈ្មោះ [redacted] គាត់កំពុងដេរខោអាវនៅក្រោមផ្ទះ បន្ទាប់មកឈ្មោះ[redacted]ត្រូវជាពូរបស់ខ្លួន បានដើរមករកខ្លួន ហើយគាត់បានឡើងទ្រាបពីលើខ្លួន ព្រមទាំងនិយាយថា បើខ្លួនហ៊ានស្រែក គាត់នឹងបេកកាំបិតមកចាក់សម្លាប់ខ្លួន រួចគាត់បានស្រាតខោខ្លួនឯង និងស្រាតខោរបស់ខ្លួន គាត់បានយកប្រដាប់ភេទគាត់ដាក់លើប្រដាប់ភេទរបស់ខ្លួន ភ្លាមនោះម៉ីងខ្លួន ឈ្មោះ[redacted]និងយាយឈ្មោះ [redacted]បានឡើងមកទាន់ ហើយឈ្មោះ[redacted]បានរត់ចុះទៅដីតែម្ដង។

-អំណានចម្លើយរបស់សាក្សីឈ្មោះ[redacted]បានឆ្លើយថា៖ នៅថ្ងៃមិនចាំខែសីហា ក្នុងឆ្នាំ ២០១០ នៅវេលាម៉ោង ១៦ និង០០នាទី ចៅស្រីខ្លួនឈ្មោះ [redacted]បានទៅដេកលេងនៅលើផ្ទះរបស់ឈ្មោះ [redacted] រីឯខ្លួនបានដើរទៅផ្ទះឈ្មោះ[redacted]នៅខាងត្បូងផ្ទះឈ្មោះ[redacted] ប្រហែលជា ១៥០ ម៉ែត្រ លុះដល់ម៉ោង ១៧ និង០០នាទី ខ្លួនក៏បានដើរទៅផ្ទះឈ្មោះ[redacted]ញ ហើយខ្លួន និងកូនស្រីខ្លួនឈ្មោះ[redacted]ត្រូវជាប្រពន្ធឈ្មោះ[redacted]បាននាំគ្នាដើរឡើងទៅលើផ្ទះ ដោយខ្លួនដើរពីក្រោយកូនស្រីខ្លួន ពេលឡើងទៅដល់ស្រាប់តែឃើញ ឈ្មោះ[redacted] កំពុងតែដេកផ្កាប់មុខទ្រាបពីលើចៅស្រីខ្លួនដោយដៃ[redacted] ម្ខាងចាប់ទាញស្រាតខោចៅស្រីរបស់ខ្លួនមកដល់ត្រឹមភ្លៅ ឯប្រដាប់ភេទរបស់ឈ្មោះ [redacted]បញ្ចេញមកក្រៅរៀបនឹងដាក់ចូលទៅក្នុងប្រដាប់ភេទចៅស្រីរបស់ខ្លួនទៅហើយ។ ពេលនោះខ្លួនមិនបានចាំថា ឈ្មោះ[redacted] ស្លៀកខោ ឬក្រម៉ាទេ លុះឃើញពួកខ្លួន ឈ្មោះ[redacted]ក៏ស្ទុះក្រោកចុះមកដីឯតទឹកទៅ រីឯចៅខ្លួនដេកផ្ងារមានសភាពស្លេកស្លាំង មិនហ៊ានស្រែកឡើយ ចាប់តាំងពីពេលនោះមកឈ្មោះ[redacted]ឧស្សាហ៍រករឿងឈ្លោះប្រកែកជាមួយខ្លួនណាស់ ព្រមកាន់កាំបិតគំរាមរកកាប់ខ្លួនទៀតផង

Scanned by CamScanner

ដោយខ្លួនខ្លាចឈ្មោះ[redacted]សម្លាប់ គឺមិនហ៊ានប្តឹងទៅប៉ុស្តិ៍នគរបាលនោះទេ គឺខ្លួនគ្រាន់តែនិយាយប្រាប់ឈ្មោះ ហេង ជាតំណាងឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ពោធិ៍ប៉ូនប៉ុណ្ណោះ។

-អំណានចម្លើយសាក្សីឈ្មោះ[redacted]នឆ្លើយថា៖ កាលពីថ្ងៃទីមិនចាំអំឡុងខែឧសភា ឆ្នាំ២០១០ វេលាម៉ោងប្រហែល ២ រសៀល ខ្លួនរួមជាមួយក្មួយស្រីខ្លួនឈ្មោះ[redacted]យុ ១០ ឆ្នាំ បាននាំគ្នាលាងចានបាយនៅក្រោមផ្ទះ ឯប្តីខ្លួនឈ្មោះ[redacted]ងូតទឹករួចគាត់ឡើងទៅលើផ្ទះស្លៀកពាក់ខោអាវ បំរុងទៅភូមិខាងលើ ចំណែកម្តាយខ្លួនឈ្មោះ[redacted]គាត់បានដើរទៅលេងនៅផ្ទះរបស់ឈ្មោះ[redacted]គាត់ហើយ បានបន្តិចក្មួយស្រីខ្លួនឈ្មោះ[redacted]ឡើងទៅលើផ្ទះខ្លួនមិនដឹងថាឡើងទៅធ្វើអ្វីទេ បន្ទាប់មកខ្លួនក៏បានយកចានទៅទុក ពេលទៅដល់លើផ្ទះឃើញប្តីខ្លួនអង្គុយនៅក្បែរទូរ ស្លៀកខោជើងវែង ពណ៌ប្រផេះ ពាក់អាវដៃវែង ពណ៌ស ឯក្មួយស្រីខ្លួនឈ្មោះ[redacted]អង្គុយជិតចង្ក្រាន ចំងាយពីប្តីខ្លួនប្រហែលជាងមួយម៉ែត្រ ឯកូនប្រុសខ្លួនឈ្មោះ[redacted]អាយុ ៥ឆ្នាំ កំពង់ដេកនៅខាងមុខទូរ ចំណែកម្តាយខ្លួនគាត់មិនទាន់ត្រឡប់មកដល់ផ្ទះវិញទេ។ ភ្លាមនោះប្តីខ្លួនក៏បាននាំក្មួយស្រីខ្លួនទៅងូតទឹក នៅពេលងូតទឹកឲ្យក្មួយស្រីខ្លួនរួច ប្តីខ្លួនក៏ដើរទៅភូមិបាត់ទៅ រហូតដល់ម៉ោង ៥ ល្ងាច ទើបម្តាយខ្លួនមកដល់ផ្ទះខ្លួនវិញ នៅពេលខ្លួនឡើងទៅលើផ្ទះនោះ ម្តាយខ្លួនគាត់មិនទាន់មកដល់ គាត់មិនបានឡើងទៅលើផ្ទះជាមួយខ្លួនទេ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការៈ ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ និងអំណានចម្លើយសាក្សី តំណាងអយ្យការយល់ឃើញថា កាលពីខែសីហា ឆ្នាំ២០១០ ជនជាប់ចោទឈ្មោះ[redacted]ពិតជាបានជាបានរំលោភលើជនរងគ្រោះ និងយកប្រដាប់ភេទបម្រុងដាក់បញ្ចូលប្រដាប់ភេទជនរងគ្រោះ ប៉ុន្តែឈ្មោះ[redacted]នមកទាន់ ជនជាប់ចោទក៏បានបញ្ឈប់សកម្មភាពរបស់ខ្លួន ដែលអំពើនេះច្បាប់ចាត់ទុកថាជាបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។ ហេតុដូច្នេះតំណាងអយ្យការសូមរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ៖ ៦១៧ដកសព ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ទុកជាបានការទាំងស្រុង។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទៈ ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ និងអំណានចម្លើយសាក្សី ខ្លួនជាមេធាវីការពារឱ្យជនជាប់ចោទ ស្នើសុំដល់តុលាការមេត្តាពិចារណា និងសម្រេចតាមច្បាប់។

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

Scanned by CamScanner

## សាលាដំបូងខេត្តកណ្ដាល

## យល់ឃើញថា

១.ជនរងគ្រោះឈ្មោះ [redacted]ានឆ្លើយថា៖ ខ្លួនមិនបានចាំថ្ងៃខែឆ្នាំទេ វេលាម៉ោងប្រហែល ៥ ល្ងាច ខ្លួនកំពុងអង្គុយលើផ្ទះនៅក្នុងភូមិព្រែកល្វា ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល តែម្នាក់ឯង បន្ទាប់មកឈ្មោះ[redacted]ត្រូវជាពូរបស់ខ្លួន បានដើរមករកខ្លួន ហើយគាត់បានឡើងគ្រោបពីលើខ្លួន ព្រមទាំងនិយាយថា បើខ្លួនហ៊ានស្រែក គាត់នឹងយកកាំបិតមកចាក់សម្លាប់ខ្លួន រួចគាត់បានស្រាតខោខ្លួនឯង និងស្រាតខោរបស់ខ្លួន គាត់បានយកប្រដាប់ភេទគាត់ដាក់លើប្រដាប់ភេទរបស់ខ្លួន ភ្លាមនោះ[redacted]ិងបងប្រុសឈ្[redacted]ះឡើងមកទាន់ ហើយឈ្មោះ[redacted]ានរត់ចុះទៅដីតែម្ដង ដែលមានភាពស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយសាក្សីឈ្មោះ [redacted]

២.សាក្សីឈ្មោះ[redacted]នឆ្លើយថា៖ នៅថ្ងៃមិនចាំខែសីហា ក្នុងឆ្នាំ២០១០ នៅម៉ោង ១៧ និង០០នាទី ខ្លួន និងកូនស្រីខ្លួនឈ្មោះ ព[redacted]ាប្រពន្ធឈ្មោះ[redacted]ាននាំគ្នាដើរឡើងទៅលើផ្ទះ ដោយខ្លួនដើរពីក្រោយកូនស្រីខ្លួន ពេលឡើងទៅដល់ស្រាប់តែឃើញ ឈ្មោះ[redacted] កំពុងតែដេកផ្កាប់មុខគ្រោបពីលើចៅស្រីខ្លួនដោយដៃ[redacted]ម្ខាងចាប់ទាញស្រាតខោចៅស្រីរបស់ខ្លួនមកដល់ត្រឹមភ្លៅ ឯប្រដាប់ភេទរបស់ឈ្មោះ[redacted]ញ្ចេញមកត្រៀមនឹងដាក់ចូលទៅក្នុងប្រដាប់ភេទចៅស្រីរបស់ខ្លួនទៅហើយ។

៣.តាមចម្លើយជនរងគ្រោះឈ្មោះ[redacted]ងសាក្សីឈ្មោះ[redacted]បញ្ជាក់បានថា កាលពីខែសីហា ឆ្នាំ២០១០ ជនជាប់ចោទឈ្មោះ[redacted]តជាបានធ្វើសកម្មភាពចាប់ស្រាតខោជនរងគ្រោះ និងខោខ្លួនក្នុងគោលបំណងដាក់ប្រដាប់លិង្គរបស់ខ្លួន ចូលក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ ប៉ុន្តែចៃដន្យឈ្មោះ[redacted]បកទាន់ ធ្វើឱ្យជនជាប់ចោទបញ្ឈប់សកម្មភាពរបស់ខ្លួន ដែលអំពើនេះច្បាប់ចាត់ទុកជាជាបទៈ **ប៉ុនប៉ងរំលោភសេពសន្ថវៈ**។

៤.អំពើរបស់ជនជាប់ចោទឈ្មោះ[redacted]ប្រព្រឹត្តលើជនរងគ្រោះជាអនីតិជនដែលមានអាយុទើបតែ ០៩ ឆ្នាំ ដែលជាបុគ្គលមានភាពទន់ខ្សោយពិសេស ដោយមូលហេតុនៃអាយុបុគ្គល ហេតុដូច្នេះតុលាការធ្វើការកែប្រែបទចោទប្រកាន់លើជនជាប់ចោទពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ** មកបទៈ **ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ**។

៥.អំពើរបស់ជនត្រូវចោទឈ្មោះ[redacted]ប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសង្គម កិត្តិយស និងរូបកាយរបស់ជនរងគ្រោះ ហើយជនត្រូវចោទជានីតិជន មានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ។

Scanned by CamScanner

៦ មានភស្តុតាង និង[illegible]គ្រប់គ្រាន់លើឈ្មោះ[redacted]ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ ពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) ប្រព្រឹត្តនៅភូមិព្រៃកល្ងា ឃុំព្រៃកតាកូវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពី ខែសីហា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

៧.ជនជាប់ចោទឈ្មោះ[redacted]ប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ បានរត់គេចខ្លួន ហើយអំពើរបស់ជនជាប់ចោទត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារលើសពីមួយឆ្នាំ គប្បីសាលាដំបូងខេត្តកណ្ដាល ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទ[redacted]ទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេចសេចក្ដី

១/កែប្រែបទចោទប្រកាន់លើឈ្មោះ[redacted]ភេទប្រុស អាយុ ៥៨ឆ្នាំ ពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ មកបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

២/ផ្ដន្ទាទោសៈ ឈ្មោះ[redacted]ទប្រុស អាយុ ៥៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ៧ ឆ្នាំ (ប្រាំពីរឆ្នាំ) ពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) ប្រព្រឹត្តនៅភូមិព្រៃកល្ងា ឃុំព្រៃកតាកូវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីខែសីហា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

៣/ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ[redacted]ទប្រុស អាយុ ៥៨ឆ្នាំ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នាថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ កំបាំងមុខជនជាប់ចោទ។

ទុកសិទ្ធប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមក្រុមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] [redacted] | [redacted] |

**បានឃើញ**
ចៅក្រម

[redacted]

[redacted]ចម្លងត្រឹមត្រូវតាមច្បាប់ដើម
កណ្ដាល, ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤
**ក្រឡាបញ្ជីសវនាការ**

[redacted]

Scanned by CamScanner